ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 05 / 2016
ម៉ោង (Time/Heure) : 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
**E1/407**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៣៨៨

រៀបចំដោយ៖ **ឯម ហ៊ីយ** និង Niccolo PONS

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ីយ, លោក Niccolo PONS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN, លោក សេង លាង |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន ៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក វ៉ែន ពៅ, លោក ឡោ ជុនធី, លោក ហុង គីមសួន, លោកស្រី ទី ស្រីនណា |

| |
|---|
| អ្នកជំនាញ ៖ អ៊ីសា ឧស្មាន (2-TCE-95) , លោកស្រី Julie BARDECHE ជាមន្ត្រីច្បាប់របស់ OCIJ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោកស្រី សំ មករា , លោក មៀច សុវណ្ណា, កញ្ញា សុក សុភ័គគមណីកា , លោកស្រី ពេជ ចរិយា, លោក Lachlan Slattery . |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១៦.០៩ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៧ | បញ្ចប់ម៉ោង៖ ១០.៣៩ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៩ | បញ្ចប់ម៉ោង៖១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៦ | បញ្ចប់ម៉ោង៖ ១៥.០៧ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៣៣ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៦ | ០៩.០៧ |
| ចម្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្ដី នួន ជា ស្របតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង ដើម្បីស្ដាប់សាក្សីបន្ថែមទាក់ទងទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល និងទទួលយកកំណត់នៃការស្ដាប់ចម្លើយសាក្សីដែលបានធ្វើសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៧<br>០៩.០៩<br>០៩.១៨<br>០៩.២០<br>០៩.២០ | ០៩.២៦<br>០៩.២៣<br>០៩.១៩<br>០៩.២០<br>០៩.២៧ |
| ការតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.២៧<br>០៩.២៧<br>១៥.២៦ | ០៩.២៧<br>១៥.១១<br>១៦.០៨ |

| | | | |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់លើការប្រើប្រាស់សំណួរជាមូលដ្ឋានដោយផ្អែកលើព័ត៌មាននៅក្នុងចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម | សហព្រះរាជអាជ្ញាអន្តរជាតិ<br>មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ | ១៤.១៣<br>១៤.១៤<br>១៤.១៥<br>១៤.២០ | ១៤.១៤<br>១៤.២៤<br>១៤.៣១<br>១៤.២១ |
| សំណើរបស់មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និង សហព្រះរាជអាជ្ញា លើការស្នើសុំពេលវេលាបន្ថែមដើម្បីតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) ហើយមេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ក៏ស្នើសុំឱ្យមានសវនាការអសាធារណៈលើអ្នកជំនាញ អ៊ីសា ឧស្មាន(2-TCE-95)ផងដែរ | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ១៥.០៩<br>១៥.១០<br>១៥.១៣<br>១៥.១៧<br>១៥.១៧ | ១៥.១០<br>១៥.១២<br>១៥.១៧<br>១៥.១៧<br>១៥.១៨ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការឆ្លើយតបផ្ទាល់មាត់ទៅមេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន៨៧(៤) ស្នើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែមទាក់ទងទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល និងទទួលយកកំណត់នៃការស្តាប់ចម្លើយសាក្សីដែលបានធ្វើសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា</u>**

មេធាវីការពារក្តី នួន ជា បានស្នើសុំស្តាប់សាក្សីបន្ថែមទាក់ទងទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល និងទទួលយកកំណត់នៃការស្តាប់ចម្លើយសាក្សីដែលបានធ្វើសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៧ ក្នុងការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីស្តាប់សក្ខីកម្ម

សាក្សីចំនួនពីររូបបន្ថែមទៀតសម្រាប់អង្គហេតុនៃមន្ទីរសន្តិសុខភ្នំក្រោល ជំនួសឱ្យសាក្សីដែលទទួលមរណភាពនាពេលថ្មីៗនេះ [ជាការកត់សំគាល់ថា មានការភាន់ច្រឡំខ្លះចំពោះថាតើការផ្តល់សក្ខីកម្មរបស់សាក្សីធ្វើឡើងនៅក្នុងឆ្នាំ ២០០៧ ឬ ២០០១] ។ មេធាវីការពារក្តី នួន ជា បានអះអាងថា សាក្សីរូបនេះមានការជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅមណ្ឌលគិរី និងនៅភូមិភាគឥសានទាំងមូល ចន្លោះពីឆ្នាំ ១៩៧៥ និង ១៩៧៩ ។ មេធាវីការពារក្តី នួន ជា ក៏បានបញ្ជាក់ទៀតថា ការដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលធ្វើការសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ (E3/7960) ទំនងមិនអាចត្រឹមត្រូវបានទេ។ ហេតុដូច្នេះហើយ ឯកសារថតសំលេងដើមនៃការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៣ ខែមីនា ២០០៧ គួរត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។

សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងការស្នើសុំរបស់មេធាវីការពារក្តី នួន ជា នោះទេ។

មេធាវីការពារក្តី ខៀវ សំផន មិនបានជំទាស់ទៅនឹងការស្នើសុំរបស់មេធាវីការពារក្តី នួន ជា ផងដែរ។

**<u>ការតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ុំសា ឧស្មាន</u>** <u>(2-TCE-95)</u>

មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់អ្នកជំនាញ (2-TCE-95) ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើការប្រើប្រាស់សំណួរជាមូលដ្ឋានដោយផ្អែកលើព័ត៌មាននៅក្នុងចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម</u>**

សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការសួរសំណួររបស់ មេធាវីការពារ នួន ជា ទាក់ទងទៅនឹងចម្លើយសារភាពដែលទទួលបានមកពីមន្ទីរសន្តិសុខក្រូចឆ្មា ដោយសំអាងថា មេធាវីការពារក្តី នួន ជា មិនបានទទួលបន្ទុកក្នុងការបង្កើត ថាតើភ័ស្តុតាងនោះ ទទួលបានពីការធ្វើទារុណកម្ម ឬយ៉ាងណា។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សេចក្តីសម្រេច E350/8 ចាត់ទុក "ចម្លើយសារភាពមកពី ស-២១ និងមន្ទីរសន្តិសុខផ្សេងៗទៀត មានហានិភ័យច្បាស់ណាស់ ដែលចម្លើយសារភាពទាំងនោះ ទទួលបានមកដោយការធ្វើទារុណកម្ម" ។

ចៅក្រម Lavergne បានចេញសេចក្តីសម្រេចផ្ទាល់មាត់ ប្រសិនគោលបំណងនៃការសួរសំណួរទៅកាន់អ្នកជំនាញ សួរថាតើមានការធ្វើទារុណកម្មដែរឬអត់ដែលបានអនុវត្តនៅមន្ទីរសន្តិសុខក្រូចឆ្មារ ក្នុងករណីនេះគឺអាចសួរបាន។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនសំណួរ សំណួរណាមួយដែលប្រើប្រាស់ព័ត៌មានដែលទទួលបានពីការធ្វើទារុណកម្ម គឺសំណួរនោះមិនត្រូវបានអនុញ្ញាតឱ្យសួរឡើយ។

**សំណើសុំរបស់ភាគីស្នើសុំពេលបន្ថែម ដើម្បីតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95)**

មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និងសហព្រះរាជអាជ្ញាបានស្នើថា ពេលវេលាបន្ថែមគួរត្រូវបានអនុញ្ញាតទៅភាគីនីមួយៗ សម្រាប់ការតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) ។ អង្គជំនុំជម្រះបានអនុញ្ញាតបន្ថែមពេលវេលាមួយវគ្គដល់សហព្រះរាជអាជ្ញា និងបន្ថែមពេលវេលាកន្លះថ្ងៃដល់ក្រុមការពារក្តីទាំងពីរ។

**មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យមានសវនាការអសាធារណៈក្នុងការតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95)**

មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យមានសវនាការអសាធារណៈក្នុងការតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) នៅរសៀលនៃថ្ងៃទី ២៤ មីនា ២០១៦ ហើយអង្គជំនុំជម្រះក៏បានអនុញ្ញាតតាមសំណើនេះ និងក្រោយមកត្រូវបានស្នើសុំដកចេញវិញ ដោយក្រុមមេធាវីការពារក្តី។

Reclassified

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1822 | / | 00338995-00339006, 00078437-00078604, 00758327-00758335 | YSA Osman entitled: "OUKOUBAH - Justice for the Cham Muslims under the Democratic Kampuchea Regime" | P | / | 00078599 | / |
| E3/2653 | D196.2 | 00904196-00904430, 00219050-00219245, 00943973-00943985 | YSA Osman, "The Cham Rebellion: Survivors' Stories from the Village", DC-Cam, 2006 | P | 002044459? 9:48 am | 00274703 | 00224113 |
| E3/7675 | D125/100.1 | 00221852-00221855, 00293924-00293927, 00221856-00221860 | Annex 1: Interview of MAN Sen (Zain) in "The Cham Rebellion, Survivors' Stories from the Villages", YSA Osman Documentation Series No. 9, DC-Cam 2006 | P | 00221853 | 0022181859 | 00293925 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/5261 | D166/58 | 00250940-00250950, 00274333-00274341, 00285326-00285337 | Written record of Interview of SAU Seimech | P | 00250947 | 00274336 | 00285329 |
| E3/387 | D248/2.2 | 00379481-00379518, 00350200-00350231, 00441411-00441453 | Transcript of interview between Ouk Bunchhoeun conducted by Steve Heder | P | 00379487 | 00350206 | 00441418-19 |
| E3/1822 | / | 00338995-00339006, 00078437-00078604, 00758327-00758335 | OUKOUBAH, By YSA Osman | P | 00339045 | 00078597-599, 0000784 | |
| E3/7525 | / | 00089586-00089632, 00324153-00324154, 00630809-00630809 | Interviewed of brother Chann Kea, Chann Sok (IO9493)DC-Cam | P | / | / | / |
| E3/2649 | D196.11 | 00660583-00660620, 00208385-00208410, 00614102-00614124 | Annex B 0010: Henri LOCARD, "Report: Kampong Cham: West Bank of the Mekong (Old North Region), 2007 | P | / | / | / |
| E3/9333 | D125/75.1 | 00204448-00204450, 00204451-00204453, 00224115-00224116 | Annex 1: Interview of NO Satas in "The Cham Rebellion, Survivors' Stories from the Villages", Ysa Osman, Documentation series No. 9, DC-Cam, 2006 | P | 00204448-49 | 00204453 | 00224115 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៧)
- សេចក្តីសម្រេចផ្ទាល់មាត់លើការប្រើប្រាស់សំណួរជាមូលដ្ឋានផ្អែកលើព័ត៌មាននៅក្នុងចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម។ (១៤.២១)
- អនុញ្ញាតឱ្យមានពេលវេលាបន្ថែមសម្រាប់ភាគីក្នុងការតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន

01244175



(2-TCE-95) ។ (១៥.២៦)

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦។ (១៦.០៩)

| **<u>កាលវេលាសវនាការបន្ត</u>** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឯម ហ៊ុយ** ...blo PONS